ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រែក្លាយសាលាជំនាញឯកទេសចម្រុះតេជោ
## វិទ្យាស្ថានបច្ចេកទេសយោធា តេជោ ហ៊ុន សែន

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ខែវិច្ឆិកាឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស

-បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ៣១ អនក្រ.បក ចុះថ្ងៃ ទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ៨៥ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានប្រែក្លាយសាលាជំនាញឯកទេសចម្រុះទៅជា **វិទ្យាស្ថានបច្ចេកទេសយោធា តេជោ ហ៊ុន សែន** ដែលសរសេរកាត់ថា **វ.ប.យ.ហ.ស.** ជាភាសាអង់គ្លេស **Techo Hun Sen Military Technical Institute (H.S.M.T.I)** ដើម្បីបណ្តុះបណ្តាលធនធានមនុស្សដល់យោធិន នៃកងយោធពលខេមរភូមិន្ទ ក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ភារកិច្ច និងការគ្រប់គ្រង

**មាត្រា២.-**

**វ.ប.យ.ហ.ស.** មានភារកិច្ចបណ្តុះបណ្តាល និងវិក្រឹត្យការលើមុខជំនាញបច្ចេកទេស ស្រាវជ្រាវបច្ចេកវិទ្យាយោធា និងចំណេះដឹងទូទៅដល់យោធិននៃកងយោធពលខេមរភូមិន្ទ និងបណ្តុះបណ្តាលមុខជំនាញបច្ចេក

ទេសយោធាកម្រិតបច្ចេកទេសមធ្យម បរិញ្ញាបត្រ វិស្វករ និងបរិញ្ញាបត្រជាន់ខ្ពស់ ។

**មាត្រា៣.-**

**វ.ប.យ.ហ.ស.** ធ្វើការបណ្តុះបណ្តាលលើមុខជំនាញដូចខាងក្រោម ÷

- បច្ចេកទេសយន្តសាស្ត្រ
- បច្ចេកទេសសញ្ញាវុធ
- ឯកទេសវិស្វកម្ម ភូមិសាស្ត្រ អគ្គិសនី អេឡិចត្រូនិក និងវិទ្យុទូរគមនាគមន៍
- គីមីសាស្ត្រ
- ស្រាវជ្រាវបច្ចេកវិទ្យាយោធា

ទៅថ្ងៃអនាគតយោងតាមតម្រូវការចាំបាច់ក្នុងវិស័យការពារជាតិ **វ.ប.យ.ហ.ស.** អាចពង្រីកកម្រិតបណ្តុះបណ្តាលរបស់ខ្លួនបន្ថែមទៀតបាន ។

**មាត្រា៤.-**

**វ.ប.យ.ហ.ស.** ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការពារជាតិ ។ **វ.ប.យ.ហ.ស.** មានទីតាំងនៅឃុំសំរោងទង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

**មាត្រា៥.-**

**វ.ប.យ.ហ.ស.** ដឹកនាំដោយនាយក ០១ ( មួយ ) រូប អមដោយនាយករងចំនួន ០៣ ( បីរូប ) ជាជំនួយការ ។

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ **វ.ប.យ.ហ.ស.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

## ជំពូកទី៣

## កម្មវិធីសិក្សា លក្ខខណ្ឌជ្រើសរើស និងការផ្តល់សញ្ញាបត្រ

**មាត្រា៦.-**

**វ.ប.យ.ហ.ស** ត្រូវរៀបចំកម្មវិធីសិក្សាបច្ចេកទេសយោធាគ្រប់កម្រិត និងគ្រប់ជំនាញ ដោយមានការឯកភាពពីក្រសួងការពារជាតិ ។

ក្រសួងការពារជាតិ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវសហការរៀបចំកម្មវិធីសិក្សាផ្នែកចំណេះដឹងទូទៅ និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀននៅ **វ.ប.យ.ហ.ស.** តាមតម្រូវការនៃការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យការពារជាតិ ។

**មាត្រា៧.-**

លក្ខខណ្ឌនៃការជ្រើសរើសយោធិនឱ្យចូលសិក្សានៅ **វ.ប.យ.ហ.ស.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ដោយអនុលោមទៅតាមបទដ្ឋានស្តីពីការកំណត់លក្ខខណ្ឌនៃការចូលរៀននៅឧត្តមសិក្សា និងការសិក្សាជំនាញឯកទេស ។

**មាត្រា៨.-**

និស្សិតយោធិនដែលបានរៀនចប់តាមកម្មវិធីសិក្សារបស់ **វ.ប.យ.ហ.ស.** ហើយបានទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា ។

សញ្ញាបត្រនេះ ត្រូវចុះហត្ថលេខាដោយនាយក **វ.ប.យ.ហ.ស.** និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ។

សញ្ញាបត្របញ្ចប់ការសិក្សាដែលទទួលបាននៅ **វ.ប.យ.ហ.ស.** មានតម្លៃសមមូលនឹងសញ្ញាបត្រនៃកម្រិតបណ្តុះបណ្តាលនៅគ្រឹះស្ថានឧត្តមសិក្សា ។

## ជំពូកទី៤

## ប្រភពធនធាន

**មាត្រា៩.-**

**វ.ប.យ.ហ.ស.** មានប្រភពធនធានមកពី ÷

- ថវិកាជាតិ ដែលស្ថិតក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងការពារជាតិ
- អំណោយពីសប្បុរសជននានា ។

**វ.ប.យ.ហ.ស.** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀតពីប្រភពក្នុង និងក្រៅប្រទេសសម្រាប់បម្រើសេចក្តីត្រូវការក្នុងការបំពេញការងាររបស់ខ្លួន ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ១ ឆ្នាំ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ